ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 25 / 04 / 2012
ម៉ោង (Time/Heure) : 14:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

002/19-09-2007-ECCC/TC
E1/57

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>

## <u>សាធារណៈ</u>

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

## ថ្ងៃចន្ទ ទី០២ ខែមេសា ឆ្នាំ២០១២

## សវនាការលើអង្គសេចក្តី - ថ្ងៃទី ៤៥

រៀបចំដោយ: សែ កុលវុឌ្ឍី និង **Roger PHILLIPS**

---

| <u>កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ</u> |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី និង ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, លោក Roger PHILLIPS, លោក ឌុច ផារី |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង, លោក William SMITH, លោក Mr. Dale Lysak, លោក ប៉ាក ចន្ទលីណូ ។ |
| ជនជាប់ចោទ៖ អៀង សារី, នួន ជា, ខៀវ សំផន |

| |
|---|
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Michiel PESTMAN, លោក Jasper PAUW។ |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោក Arthur VERCKEN |
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT , លោក ហុង គីមសួន, លោកស្រី Lyma NGUYEN, លោកស្រី ស៊ិន សុវ៉ន, លោកស្រី ជេត វណ្ណលី, លោក វ៉េន ពៅ, លោក Barnabé NEKUIE, លោកស្រី Marie GUIRAUD ។ |
| សាក្សី៖ កាំង ហ្គេកអ៊ាវ ហៅ ឌុច (TCW-281) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ កញ្ញា Alexandra PRASSOLOFF |

**ពេលវេលាទូទៅរបស់តុលាការ៖**

| | | |
|---|---|---|
| ថ្ងៃចន ១០២ ខែមេសា ឆ្នាំ ២០១២ | ចាប់ផ្ដើមម៉ោង៖ ៩.៣០ | បញ្ចប់ម៉ោង៖ ១៦.២០ (៦ម៉ោង និង ៥០ នាទី) |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.៤០ | បញ្ចប់ម៉ោង៖ ១១.០០ (២០នាទី) |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១២.០០ | បញ្ចប់ម៉ោង៖ ១៣.៣០ (១ម៉ោងនិង ៣០នាទី) |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.៥៥ | បញ្ចប់ម៉ោង៖ ១៥.១៥ (២០នាទី) |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ **០៤ ម៉ោង និង៤០ នាទី** | | |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការបន្តតាំងសំណួរទៅ សាក្សី កាំង ហ្គេកអ៊ាវ | សហព្រះរាជអាជ្ញា<br>មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី | ០៩.៣០<br>១១.០០ | ១០.៣៥<br>១៦.២០ |
| សំណើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ | មេធាវីការពារឱ្យអៀង សារី<br>មេធាវីការពារឱ្យ នួន ជា | ១០.៣៥<br>១២.០០ | ១០.៣៥<br>១២.០០ |
| សំណើសុំពេលវេលាដែលនៅសល់សម្រាប់ការតាំងសំណួរទៅសាក្សី | មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី | ១៣.៣៥<br>១៥.៣០ | ១៣.៤០<br>១៥.៤០ |

| | | | |
|---|---|---|---|
| ការជំទាស់ចំពោះវិសាលភាពនៃការតាំងសំណួរទៅសាក្សី | មេធាវីការពារឱ្យអៀង សារី | ១៣.៤០ | ១៣.៤៥ |
| សំណើសុំបែងចែកពេលវេលា សម្រាប់ក្រុមមេធាវីការពារក្តីក្នុងការតាំងសំណួរទៅសាក្សី កាំង ហ្គេកអ៊ាវ | មេធាវីការពារឱ្យ នួន ជា មេធាវីការពារឱ្យខៀវ សំផន មេធាវីការពារឱ្យអៀង សារី អង្គជំនុំជម្រះ | ១៥.១៥ | ១៥.៣៥ |
| ការពិភាក្សាអំពីវិធាននៃភស្តុតាងដែលអង្គជំនុំជម្រះយកមកពិចារណាក្នុងការចេញសេចក្តីសម្រេច | មេធាវីការពារឱ្យខៀវ សំផន មេធាវីការពារឱ្យអៀងសារី អង្គជំនុំជម្រះ | ១៥.១៥ | ១៥.៤៥ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីដោយចាប់ផ្តើមពីម៉ោង ៩ និង ៣០ នាទី ដោយសារការដឹកជញ្ជូនបុគ្គលិករបស់តុលាការមានការយឺតយ៉ាវបណ្តាលមកពីការស្ទះចរាចរណ៍។

**<u>ការបន្តតាំងសំណួរទៅសាក្សី កាំង ហ្គេកអ៊ាវ</u>**

សហព្រះរាជអាជ្ញាអន្តរជាតិបានបន្ត និងបញ្ចប់ការតាំងសំណួរទៅសាក្សី កាំង ហ្គេកអ៊ាវ។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានចាប់ផ្តើមតាំងសំណួរទៅសាក្សីរូបនេះ។

**<u>សំណើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ</u>**

ជនជាប់ចោទ អៀង សារី និង នួន ជា តាមរយៈមេធាវីរបស់គាត់ បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ ដោយសុំចូលរួមសវនាការពីបន្ទប់រង់ចាំតាមរយៈប្រព័ន្ធសោតទស្សន៍។ អង្គជំនុំជម្រះទទួលយកសំណើសុំនេះ។

**<u>សំណើសុំពេលវេលានៅសល់សម្រាប់ការតាំងសំណួរទៅសាក្សី</u>**

មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឱ្យអង្គជំនុំជម្រះបញ្ជាក់អំពីពេលវេលាដែលនៅសល់សម្រាប់ពួកគេក្នុងការតាំងសំណួរទៅសាក្សី។ អង្គជំនុំជម្រះបានបញ្ជាក់ថា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានពេលវេលារហូតដល់បញ្ចប់សវនាការក្នុងថ្ងៃនេះ ក្រោយមកអង្គជំនុំជម្រះសម្រេចបន្ថែមឱ្យមួយម៉ោងទៀត។

**<u>ការជំទាស់ចំពោះវិសាលភាពនៃការតាំងសំណួរទៅសាក្សី</u>**

មេធាវីការពារឲ្យ អៀង សារី បានស្នើសុំឲ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីតាំងសំណួរទៅសាក្សីទាក់ទងនឹងអង្គហេតុដែលមាននៅក្នុងសំណុំរឿងលេខ០០២/០១។ អង្គជំនុំជម្រះបានរំលឹកទៅភាគីឲ្យប្រើប្រាស់ឈ្មោះ រហស្សនាមនៅពេលដែលពួកគេនិយាយសំដៅទៅលើសាក្សីណាមួយដែលនឹងត្រូវកោះហៅដោយតុលាការ ហើយការតាំងសំណួរទៅសាក្សីត្រូវតែទាក់ទងទៅនឹងអង្គហេតុសម្រាប់សវនាការវគ្គទីពីរនេះ។

**សំណើសុំបែងចែកពេលវេលាសម្រាប់ក្រុមមេធាវីការពារក្តីក្នុងការតាំងសំណួរទៅសាក្សី**

មេធាវីការពារឲ្យ នួន ជា បានស្នើសុំឲ្យអង្គជំនុំជម្រះបញ្ជាក់អំពីពេលវេលាដែលត្រូវបែងចែកឲ្យទៅក្រុមមេធាវីការពារក្តីទាំងអស់ក្នុងការតាំងសំណួររទៅសាក្សី ដែលក្រុមខ្លួនស្នើសុំចំនួន២ថ្ងៃ។ មេធាវីការពារឲ្យ អៀង សារីបានបញ្ជាក់ថាក្រុមខ្លួនត្រូវការរយៈពេលពីរថ្ងៃ អាស្រ័យទៅលើអ្វីដែលបានសួរដោយក្រុមមេធាវីផ្សេងៗទៀត។ អង្គជំនុំជម្រះបានធ្វើការបញ្ជាក់ថា ក្រុមមេធាវីការពារក្តីទាំងអស់មានរយៈពេលបីថ្ងៃក្នុងការតាំងសំណួរទៅសាក្សីរូបនេះ។

**ការពិភាក្សាអំពីវិធាននៃភស្តុតាងដែលអង្គជំនុំជម្រះយកមកពិចារណាក្នុងការចេញសេចក្តីសម្រេច**

មេធាវីការពារឲ្យ ខៀវ សំផន បានស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការបញ្ជាក់អំពីឯកសារ ដែលអង្គជំនុំជម្រះយកធ្វើជាមូលដ្ឋានក្នុងការចេញសេចក្តីសម្រេចរបស់ខ្លួន។ អង្គជំនុំជម្រះបានថ្លែងថា អង្គជំនុំជម្រះផ្អែកតាមវិធាន៨៧.៣ ក្នុងការដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ។ នៅពេលដែលសាក្សីមកផ្តល់សក្ខីកម្ម គ្រប់ឯកសារដែលទាក់ទងនឹងសក្ខីកម្មរបស់សាក្សីរូបនេះ ត្រូវបានចាត់ទុកថាបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/11 | D243/ 2.1.12 | 00063116-00063187 00486212-00486266 00492795-00492857 | [លិខិតបញ្ជាក់ការជំនួសឯកសារ] ទង់បដិវត្ត លេខ ពិសេស កញ្ញា 1977 CPK Magazine entitled: " The Revolutionary Flag", Special Issue, September 1977 (FULL) CPK Magazine entitled: " The Revolutionary Flag", Special Issue, September 1977 (FULL) | P | | 00486228; 00486230 | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/182 | 13.2 | 00019108-00019126 00183393-00183408 00292868-00292886 | ការប្រជុំអចិន្ត្រៃយ៍ថ្ងៃទី ៩ តុលា ៧៥<br>Permanent 's meeting of committee on 9 October 1975<br>La réunion du Comité Permanent du 9 octobre 1975 | P | 0009108 | | |
| E3/107 | D89 | 00197967-00197977 00198217-00198225 00197978-00197986 | [លិខិតបញ្ជាក់ការជំនួសឯកសារ] កំណត់ហេតុនៃការសួរចម្លើយ ឌុច ចុះថ្ងៃទី ២៤ មិថុនា ២០០៨<br>Written Record of Interview of Duch by CIJ on 24-06-2008<br>Procès verbal d'interrogatoire de Duch par CJI le 24-06-2008 | P | | 00198219 | |
| E3/12 | 6.3 | 00003136-00003142, 00000758-00000764 00182809-00182814 00224363-00224367 | សេចក្តីសំរេចរបស់គណៈមជ្ឈឹមអំពីបញ្ហាផ្សេងៗមួយចំនួន<br>Decision of central committee on a number of problems<br>Decision of central committee on a number of problems | P | | 00182814 | |
| E3/357 | D120 | 00242917-00242927 00242928-00242938 00242939-00242948 | កំណត់ហេតុនៃការសួចម្លើយឌុច ថ្ងៃទី ២៧ វិច្ឆិកា ឆ្នាំ២០០៨<br>Written Record of Interview of Duch by CIJ on 27-11-2008<br>Procès verbal d'interrogatoire de Duch par CJI le 27-11-2008 | P | | 00242931 | |
| E3/1551 | 16.67 | 00072558-00072558 | ឈ្មោះអ្នកទោស ក្រសួងពាណិជកម្មរដ្ឋ | P | 00367432 | | |
| E3/1552 | D288/4.65.1 | 00367632-00367708 00367432-00367530 00367531-00367631 | ប្រតិចារិតនៃដំណើរការនីតិវិធីជំនុំជម្រះករណី ឌុច - ១៩ សីហា ២០០៩<br>Transcript of Proceedings - "Duch" Trial - 19 August 2009<br>Transcript of Proceedings - "Duch" Trial - 19 August 2009 | P | | | |
| E3/342 | D288/6.68.1 | 00329596-00330129 00329596-00330129 | ឧបសម្ព័ន្ធ ១៖ ការពិនិត្យឡើងវិញបញ្ជីអ្នកទោសនៅមន្ទីរស ២១<br>Annex 1: Revised S-21 Prisoner List | P | | | |
| E3/963 | D108/26.282 | 00086716-00086717 00181772-00181774 | ឈ្មោះមនុស្សនៅ ក្រសួងការបរទេស ដែលជាប់ចម្លើយខ្មាំង<br>Annex 282: S-21 Prisoner List containing names of implicated persons from the Ministry of Foreign Affairs | P | 0086716 | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/1140 | D288/ 5.210 | 00052994- 00052994 00178065- 00178065 00195953- 00195953 | សំបុត្រ ស៊ូ ម៉េត ផ្ញើរទៅ ឌុច មានចំណងជើងថា" ជូនចំពោះសមមិត្ត ឌុចជាទីស្នេហា" ថ្ងៃទី ០១ មេសា ១៩៧៧ Sou Met's letter to Duch entitled "Dear Beloved Comrade KAING Guek Eav alias Duch." 01 April 1977 Lettre de Sou Met à Duch "Bien aimé camarade Kaing Guek Eav alias Duch" 1er Avril 1977 | P | 00052994 | 00178065 | |
| E3/971 | D288/ 5.211 | 00178066- 00178066 | Sou Met's letter to Duch entitled "Dear Beloved Comrade KAING Guek Eav alias Duch." 01 May 1977 | P | | 00178066 | |
| E3/1043 | D108/ 31.40 | 00280086- 00280086, 00002078- 00002078 00224319- 00224319, 00178193- 00178193 00238846- 00238846 | ជំរាបមក ឌុច អំពីចម្លើយរបស់ សែម Annex 40: Report from SOU Met to KAING Guek Eav alias Duch that requests information regarding the confessions of Sem, of Battalion 512 Annex 40: Report from SOU Met to KAING Guek Eav alias Duch that requests information regarding the confessions of Sem, of Battalion 512 | P | 00002078 | 00224319 | |
| E3/259 | 9.2 | 00089841- 00089852 00184833- 00184839 S 00012644- 00012659 | សំណុំឯកសារច្បាប់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យមានចំណង រដ្ឋធម្មនុញ្ញនៃកម្ពុជាប្រជាធិបតេយ្យ DK Government Legal Documents entitled Constitution of Democratic Kampuchea Swedish Collection Document 1976 | P | | | |
| E3/727 | 11.14 | 00064551- 00064585 00185322- 00185347 00524447- 00524475 | ទង់បដិវត្ត លេខពិសេស ឧសភា មិថុនា ១៩៧៨ Tung Pakdevath No. 8 August, 1978 Tung Pakdevath No. 8 August, 1978 | P | 00064566 | 00185332 | |
| E3/1553 | D108/ 26.272 | 00088751- 00088753 | បញ្ជីរាយនាមអ្នកទោស៧នាក់ដែលជាជនជាតិអាមេរិចកាំង និងវៀតណាមដែលត្រូវបានចាប់ខ្លួននៅថ្ងៃ២៦ ១១ ១៩៧៨ | P | | | |
| E3/1554 | D22/2 1/3 | 00211734- 00211758 00335569- 00335579 00323822- 00323835 | ឧបសម្ព័ន្ធ៣ ទិន្នន័យមជ្ឈមណ្ឌលឯកសារកម្ពុជារបស់លោក មីហ្សែល ស្កុត ឌីដ Annex 3: Confession of Mr. Michael Scott DEEDS at Tuol Sleng Annex 3: Confession de M. Michael Scott DEEDS á Tuol Sleng | P | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/1555 | D130/8 | 00355904-00355917<br>00355926-00355933<br>00355918-00355925 | ដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយ ការធ្វើទារុណកម្ម<br>Order on use of statements which were or may have been obtained by torture<br>Ordonnance sur l'utilisation des éléments obtenus ou susceptibles d'avoir été obtenus sous la torture | P | | | |

**<u>ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖</u>**

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតិឲ្យជនជាប់ចោទ អៀង សារី (១០.៣៧) និង នួន ជា (១២.០០) ចូលរួមដំណើរការសវនាការពីបន្ទប់រង់ចាំខាងក្រោមសាលសវនាការ និងបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់រង់ចាំ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទទាំងពីរមានភ្ជាប់មកជាមួយនឹងកំណត់ហេតុនេះ)។
- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំសាក្សី កាំង ហ្កេកអ៊ាវ ហៅឌុច ត្រឡប់ទៅមន្ទីរឃុំឃាំងវិញ និងនាំគាត់មកបន្ទប់សវនាការ នៅថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១២។
- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី នួន ជា ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទ មកកាន់បន្ទប់សវនាការវិញឲ្យបានមុនម៉ោង០៩ ព្រឹក នៅថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១២។

**<u>កាលបរិច្ឆេទបន្តសវនាការ៖</u>**

សវនាការនឹងបន្តនៅថ្ងៃអង្គារ៍ ទី ០៣ ខែ មេសា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។

ភ្នំពេញ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១២

ក្រឡាបញ្ជី　　　　ក្រឡាបញ្ជី

**សែ កុលឧត្ដម**　　　　**Roger PHILLIPS**

កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី (សវនាការលើអង្គសេចក្ដីសំណុំរឿងលេខ០០២/០១ វគ្គ២)/០២ មេសា ២០១២ /សាធារណៈ